**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ [illegible] សហវ

# ប្រកាស

## ស្ដីពី

## ការណែនាំអនុវត្តការបង់ពន្ធកាត់ទុកលើការប្រាក់ចំពោះប្រាក់ដែលខ្ចីក្នុងស្រុក និងពីបរទេសរបស់ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

## សម្រេច

### ប្រការ១.- គោលបំណង

ប្រកាសនេះ មានគោលបំណងជួយសម្រាលបន្ទុកចំណាយលើការប្រាក់ចំពោះប្រាក់ដែលខ្ចីក្នុងស្រុក និងពីបរទេសរបស់ធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ដើម្បីរក្សានិរន្តរភាពនៃវិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុ ក៏ដូចជាផ្តល់លទ្ធភាពឱ្យធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុជួយសម្រួលដល់ការបង់ប្រាក់របស់ប្រជាពលរដ្ឋ និងសហគ្រាសបាននិងកំពុងខ្ចីប្រាក់ពីធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ដែលកំពុងរងផលប៉ះពាល់ធ្ងន់ធ្ងរពីការរីករាលដាលនៃជំងឺកូវីដ-១៩។

### ប្រការ២.- វិសាលភាព

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលស្ថិតក្រោមច្បាប់និងបទប្បញ្ញត្តិក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុរបស់ព្រះរាជាណាចក្រកម្ពុជា។

### ប្រការ៣.- ការអនុគ្រោះពន្ធកាត់ទុក

១- អនុលោមតាមមាត្រា ២៥ថ្មី និងមាត្រា ២៦ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ ពន្ធកាត់ទុកលើការប្រាក់ចំពោះប្រាក់ដែលខ្ចីក្នុងស្រុកត្រូវអនុវត្តតាមអត្រា ១៥ភាគរយ និងប្រាក់ដែលខ្ចីពីបរទេសត្រូវអនុវត្តតាមអត្រា ១៤ភាគរយ ក្នុងនោះ÷

ក- ធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ដែលបានខ្ចីប្រាក់ក្នុងស្រុក ឬពីបរទេស សម្រាប់កម្ចីថ្មី វៀរលែងតែប្រាក់កម្ចីចាស់ ឬការស្នើសុំបន្ថែមលើប្រាក់កម្ចីចាស់ ត្រូវ÷

- អនុវត្តការកាត់ទុកប្រាក់ពន្ធចំនួន ៥ ភាគរយ ពីការប្រាក់ដែលបានទូទាត់ទៅឱ្យអ្នកជាប់ពន្ធនិវាសនជន និងអ្នកជាប់ពន្ធអនិវាសនជន សម្រាប់រយៈពេលជាប់ពន្ធពីខែមេសា ដល់ខែធ្នូ ឆ្នាំ២០២០
- អនុវត្តការកាត់ទុកប្រាក់ពន្ធចំនួន ១០ ភាគរយ ពីការប្រាក់ដែលបានទូទាត់ទៅឱ្យអ្នកជាប់ពន្ធនិវាសនជន និងអ្នកជាប់ពន្ធអនិវាសនជន សម្រាប់ឆ្នាំ២០២១
- អនុវត្តការកាត់ទុកប្រាក់ពន្ធតាមអត្រាធម្មតា ស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន ពីការប្រាក់ដែលបានទូទាត់ទៅឱ្យអ្នកជាប់ពន្ធនិវាសនជននិងអ្នកជាប់ពន្ធអនិវាសនជន សម្រាប់ឆ្នាំ ២០២២ តទៅ។

ខ- ធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ដែលបានខ្ចីប្រាក់ក្នុងស្រុក ឬពីបរទេស សម្រាប់កម្ចីចាស់ដែលនៅមានសុពលភាព ត្រូវ÷

- អនុវត្តការកាត់ទុកប្រាក់ពន្ធចំនួន ១០ ភាគរយ ពីការប្រាក់ដែលបានទូទាត់ទៅឱ្យអ្នកជាប់ពន្ធនិវាសនជននិងអ្នកជាប់ពន្ធអនិវាសនជន សម្រាប់រយៈពេលជាប់ពន្ធពីខែមេសា ដល់ខែធ្នូ ឆ្នាំ២០២០
- អនុវត្តការកាត់ទុកប្រាក់ពន្ធតាមអត្រាធម្មតា ស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន ពីការប្រាក់ដែលបានទូទាត់ទៅឱ្យអ្នកជាប់ពន្ធនិវាសនជននិងអ្នកជាប់ពន្ធអនិវាសនជន សម្រាប់ឆ្នាំ ២០២១ តទៅ។

២- ពន្ធកាត់ទុកដែលត្រូវបានបន្ធូរបន្ថយ ត្រូវចាត់ទុកជាបន្ទុករបស់រដ្ឋដើម្បីជាការឧបត្ថម្ភគាំទ្រដល់វិស័យធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ។

**ប្រការ៤.- ឯកសារគាំទ្រ**

ដើម្បីអនុវត្តតាមខ្លឹមសារដូចមានចែងក្នុងប្រការ ៣ នៃប្រកាសនេះ ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវមានឯកសារគាំទ្រដូចខាងក្រោម÷

១- កិច្ចសន្យាខ្ចីប្រាក់ដែលមានការបញ្ជាក់ពីមេធាវីនៃភាគីទាំងសងខាង

២- ឯកសារផ្ទេរប្រាក់ទាក់ទិននឹងកិច្ចសន្យាខ្ចីប្រាក់ និង

៣- កំណត់ត្រាត្រឹមត្រូវនិងច្បាស់លាស់ក្នុងបញ្ជីគណនេយ្យ។

ឯកសារគាំទ្រខាងលើនេះ មិនតម្រូវឱ្យភ្ជាប់ជាមួយលិខិតប្រកាសសារពើពន្ធទេ ប៉ុន្តែត្រូវរក្សាទុកសម្រាប់គោលដៅនៃការធ្វើសវនកម្មពន្ធដារ។

**ប្រការ៥.- ភារកិច្ចអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក និងអគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់គ្រឹះស្ថានពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ៥រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ